រស្មីកម្ពុជា

# ពលរដ្ឋឃុំបន្ទាយនាងសំណូមពរឱ្យលើកកម្ពស់ការពិនិត្យផ្ទៃពោះ និងសេវាផ្សេងៗទៀត




*លោកកែវ ពេជ្រសុវណ្ណ, លោកអ៊ុក មុនី និងលោកស្រីចាន់ ស៊ីណាត ចូលរួមក្នុងវេទិកាសុខភាព នៅឃុំបន្ទាយនាង (រូបថត:ភ្នំស្វាយ)*

**បន្ទាយមានជ័យ:** ប្រជាពលរដ្ឋឃុំបន្ទាយនាង ស្រុកមង្គលបូរី បានសំណូមពរដល់អ្នកគ្រប់គ្រងសេវាសុខភាព ថ្នាក់ស្រុក និងខេត្ត ឱ្យជំរុញការលើកកម្ពស់ការថែទាំ និងព្យាបាលមាតា និងទារក ក៏ដូចជា ការលើកកម្ពស់ការចាក់វ៉ាក់សាំងការពារជំងឺដល់កុមារផងដែរ។

ប្រជាពលរដ្ឋឃុំបន្ទាយនាង បាន លើកឡើង នៅក្នុងវេទិកាស្តីពី" ការពិនិត្យឡើងវិញលើសមិទ្ធផលឆ្នាំចាស់ និងទិសដៅឆ្នាំ២០១៤ ផែនការប្រតិបត្តិសុខាភិបាលថ្នាក់មណ្ឌលសុខភាព" ឃុំបន្ទាយនាង ស្រុកមង្គលបុរី កាលពីថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ២០១៤។

នៅក្នុងវេទិកានោះ ពលរដ្ឋ ប្រធាន និងសមាជិកក្រុមទ្រទ្រង់សុខភាព ភូមិនានា នៅឃុំបន្ទាយនាង បានចោទសួរ និងលើកសំណូមពរជាច្រើនទាក់ទងនឹងការនាំយកវ៉ាក់សាំងចាក់បង្ការជំងឺកញ្ជ្រិល និងជំងឺស្អូច ក៏ដូចជា ការរើសអើងនៅក្នុងសេវាបញ្ជូនស្ត្រីមានផ្ទៃពោះ ទៅសម្រាលកូននៅមន្ទីរពេទ្យ ដោយគ្មានពេទ្យឆ្មបទៅតាមជាដើម។

លោកអ៊ុក មុនី ប្រធានការិយាល័យសុខាភិបាលប្រតិបត្តិស្រុកមង្គលបូរី មានប្រសាសន៍ថា : ដូចក្រសួងសុខាភិបាលប្រកាស និងបំភ្លឺជាសាធារណៈ កុំឱ្យជឿការឃោសនាអកុសល។ តាមពិតវ៉ាក់សាំង ចាក់បង្ការជំងឺកញ្ជ្រិល និងជំងឺស្អូចនោះ ផលិតនៅប្រទេសឥណ្ឌា មិនមែនផលិតនៅប្រទេសវៀតណាមនោះទេ។ វាជាវ៉ាក់សាំងដែលល្បី និងទទួលស្គាល់គុណភាពប្រសិទ្ធភាពដោយអង្គការសុខភាពពិភពលោក (WHO)។ វាមិនប៉ះពាល់ដល់សុខភាព និងអាយុជីវិតកុមារឡើយ។

ចំពោះសំណួរថា សេវាពិនិត្យផ្ទៃពោះគ្រាន់តែអង្អែលៗ មិនដិតដល់, រើសអើង (ខ្ចីមររើម) និងការបញ្ជូនស្ត្រីផ្ទៃពោះទៅសម្រាលកូននៅមន្ទីរពេទ្យគ្មានពេទ្យឆ្មបតាម?

លោកអ៊ុក មុនី និងអ្នកស្រី ស៊ុំ បុន អនុប្រធានមណ្ឌលសុខភាពបន្ទាយនាង និងលោកវេជ្ជបណ្ឌិត កែវ ពេជ្រសុវណ្ណ ប្រធានការិយាល័យបច្ចេកទេស មន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ បានបកស្រាយប្រាប់ប្រជាពលរដ្ឋឃុំបន្ទាយនាងជាបន្តបន្ទាប់គ្នាអំពីវេជ្ជសាស្ត្រនៃការពិនិត្យផ្ទៃពោះស្ត្រីដោយផ្អែកតាមបច្ចេកទេស និងរបៀបតាមអាយុកាលនៃកូន, វាស់ឈាម, មើលទឹកនោម, ទម្ងន់ស្ត្រីជាម្តាយ, ស្តាប់កម្លាំងចលនាកូន។ល។ ឯការបញ្ជូន គឺខេត្ត/ក្រុង ស្រុក មានរថយន្តសង្គ្រោះបន្ទាន់ ១៥គ្រឿង, ឯកជនមាន១១គ្រឿង។

លោកវេជ្ជបណ្ឌិត កែវ ពេជ្រសុវណ្ណ បានបញ្ជាក់ថា ការបញ្ជូនស្ត្រីទៅសម្រាលកូននៅឯមន្ទីរពេទ្យ ត្រូវតែមានឆ្មប។ ចំពោះឃុំបន្ទាយនាងមានពលរដ្ឋរស់នៅដល់ទៅ១៩.០០០នាក់ និងមានភូមិនៅដាច់ស្រយាលមន្ទីរ និងការិយាល័យសុខាភិបាល កំពុងធ្វើផែនការបង្កើតមណ្ឌល២។ តែមណ្ឌលចាស់ពង្រីកមិនបានទេ ព្រោះត្រូវគម្រោងពង្រីកផ្លូវដែក និងផ្លូវជាតិលេខ ៥។

លោកក៏បានរំលឹកដល់ពលរដ្ឋឱ្យបង្កើនការប្រុងប្រយ័ត្ន និងបញ្ជូនស្ត្រីត្រូវឆ្លងទន្លេណាដែលងាយគ្រោះថ្នាក់ទៅសេវាសុខភាពសាធារណៈ ជាពិសេសត្រូវទៅពិនិត្យសុខភាព និងផ្ទៃពោះ ឱ្យបានទៀងទាត់។

លោក រ័ត្ន ដាស៊ីណាំង អភិបាលរងស្រុកមង្គលបូរី បានគាំទ្រចំពោះសំណូមពររបស់ប្រជាពលរដ្ឋ ហើយលោកក៏បានជំរុញឱ្យយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សុខភាពតាមរយៈសេវាបង្ការថែទាំ ព្យាបាល និងសង្គ្រោះ គឺជាបន្ទុករបស់ពលរដ្ឋផ្នែកសុខាភិបាល, អាជ្ញាធរដែនដីនិងដៃគូអភិវឌ្ឍនានាហេតុនេះត្រូវខិតខំរួមគ្នា៕

**ភ្នំស្វាយ**

